ក្រោយគ្មានផ៉បូល បណ្តោយប្រហែលពីរម៉ែត្រ ទទឹងមួយម៉ែត្រសំរាប់ដាក់សត្វ។ អាកន្លែងខាងក្រោយហ្នឹងហើយ ដែលជាថ្នាក់ឡូសសំរាប់ខ្ញុំ។ អោយតែមកផ្ទះម្តងៗ រឺត្រលប់ទៅស្ទូងវិញ មិនចាំបាច់ព្រួឡានមកប្រាប់ខ្ញុំទេ គឺខ្ញុំចាំកន្លែងខ្ញុំច្បាស់ណាស់។

ខ្ញុំមិនជាអ្នកចេះសន្សំសំចៃដូចពួកខ្មែរក្រហមទេ មានប៉ុន្មានចាយប៉ុណ្ណឹង។ មកដល់ស្ទូងភ្លាម ខ្ញុំរត់ទៅស៊ីគុយទាវពោះគោមួយចាន។ មួយចានមិនឆ្អែត ថែមមួយចានទៀត។ បើអាចានទីពីរមិនអស់ ខ្ញុំទុកវាផ្ញើនឹងចិនសិន។ ខ្ញុំរត់ទៅវត្តមួយភ្លែត មុជទឹកស្រួលបួល ទើបមកបង្ហើយអាចានសល់។ ជួនកាលរុយរោមគុយទាវគោកស្ងួត អាចិកថែមទឹកស៊ុប ទើបខ្ញុំបន្តទៅទៀត ទាល់តែអស់ពីចាន។

វិស្សមកាលតូចនៃខែចេត្រមកដល់ហើយ។ ខ្ញុំត្រលប់ទៅផ្ទះដោយរីករាយ។ លុះដល់ពេលចូល«កង» ខ្ញុំប្រាប់ម្តាយខ្ញុំថា ខ្ញុំមិនហ៊ានធ្វើដំណើរតែម្នាក់ឯងទៅវត្តស្ទូងទេ។ តាមពិត ខ្ញុំមានគំនិតគេចវេះមិនចង់





ទៅរៀន ព្រោះខ្ញុំនឹកផ្ទះពេក។ ម្តាយខ្ញុំក៏អោយបងស្រីខ្ញុំជូនមកដល់កំពង់ចម្លងទន្លេបិទ។ នៅពេលបងស្រីខ្ញុំត្រលប់ទៅដល់ទូកដវិញ ខ្ញុំក៏ទៅដល់ក្រោយគាត់ដែរ។

- បើឯងមិនព្រមទៅរៀនដូច្នេះ(បងស្រីខ្ញុំនិយាយ) ពេលត្រលប់ទៅផ្ទះវិញ អាទី(បងប្រុសទី៣ខ្ញុំ) វាយស្លាប់ហើយ។ ក្នុងចំណោមបងប្រុសខ្ញុំ៦នាក់ ខ្ញុំខ្លាចតែបងទី៣ទេ ព្រោះគាត់កាចជាងគេ ហើយវាយប្អូនៗឥតត្រាប្រណីឡើយ។ មែនទៅដល់ផ្ទះ បងទី៣ពាក់មុខយក្ខដាក់ខ្ញុំមែន។

- អ្នក(អ្នកម្តាយ) អោយឯងទៅរៀន ឯងគេច ឥលូវស្អែកឯងទៅធ្វើចំការជាមួយអាចាប(បងប្រុសទី៦)។ ឮតែបងខ្ញុំអោយទៅធ្វើចំការ ខ្ញុំសប្បាយចិត្តទៅវិញទេ។ រឿងរៀនសូត្រ ខ្ញុំលែងចង់ហើយ។

ព្រលឹមឡើង ខ្ញុំជិះរទេះជាមួយបងខ្ញុំទៅចំការនៅកោះជ័យ។ បងខ្ញុំជាអ្នកបររទេះ ចំណែកខ្ញុំទាញគោមួយទៀតដែលដើរពីក្រោយរទេះ។ រទេះគោធ្វើដំណើរត្រឹកៗតាមមាត់ទន្លេមេគង្គ។ តាមផ្លូវទៅចំការខ្ញុំរីក-រាយខ្លាំងណាស់។ ខ្ញុំគយគន់មើលដើមស្វាយធំៗ ដែលមានផ្លែស្ទើរបាក់មែក មើលផ្លែគកំពុងតែទុំ ហើយនឹកគិតក្នុងចិត្តថា អោយតែទៅដល់ចំការកោះជ័យនឹងអាលទៅលួចគប់ផ្លែគយកមកជូរចាហួយខ្មៅ។ ពេលព្រះអាទិត្យគងភ្នំ ខ្ញុំក៏ត្រលប់មកផ្ទះវិញ។ ខ្ញុំទាញគោនៅក្រោយរទេះ ដូចដែលខ្ញុំទៅចំការ។ ពេលនោះ នៅទិសខាងលិច មេឃខ្មៅងងឹត។ បន្តិចក្រោយមក ខ្យល់ព្យុះមួយយ៉ាងធំបក់បោកមកយ៉ាងខ្លាំង។ នៅលើផ្ទៃទឹកទន្លេ រលកធំៗរត់មកបុកនឹងច្រាំង បង្កើតជាសំលេងគគ្រេងគគ្រាំគួរអោយតក់ស្លុត។ ភ្លៀងធ្លាក់មកដូចគេចាក់ទឹក។ ភាពងងឹតសូន្យសុងបានមកគ្របដណ្តប់លើផ្ទៃកោះទាំងមូល។ គោដែលផ្អើលនឹងខ្យល់បក់ខ្លាំង បំរះចេញពីនឹម បណ្តាលអោយរទេះក្រលាប់



ទឹងណាត់ទឹងណែង។ គោទៅដោយគោ រទេះទៅដោយរទេះ មនុស្សទៅដោយមនុស្ស។ ខ្ញុំភ័យខ្លាំងពេក ក៏ស្រែកទូញង៉ោង រត់ទៅផ្ទះទាំងមុខស្លេកស្លាំង។ ម្តាយខ្ញុំស្ទុះមកអោបខ្ញុំ ផ្លាស់សំលៀកបំពាក់អោយ។ បងប្រុសទីពខ្ញុំដែលឥតធម៌មេត្តា ស្រែកមកកាន់ខ្ញុំ :

- ម៉េចទៅអ្ហា សប្បាយទេធ្វើចំការ?

ស្អែកឡើង ខ្ញុំស្ពាយកំប្រោងផ្តៅចុះពីលើផ្ទះ ដើរសំដៅទៅមាត់កំពង់ចាំទូកដបណ្តោយ(ទូកដចែវស្របតាមដងទន្លេ)។ ម្តងនេះខ្ញុំតាំងចិត្តទៅរៀនមែនទែនហើយ តែខ្ញុំមិនត្រលប់ទៅស្ទួងវិញទេ គឺខ្ញុំត្រលប់ទៅវត្តថ្មគោល។ ពេលទៅដល់វត្ត ខ្ញុំស្ទុះទៅថ្វាយបង្គំលោកគ្រូអាចារ្យដេត ហើយទូលលោកថា :

- ខ្ញុំកាណាលែងទៅស្ទួងវិញហើយ ព្រោះនឹកផ្ទះខ្លាំងណាស់។ សូមលោកគ្រូអនុញ្ញាតអោយនៅត្រឹមវត្តថ្មគោលបានហើយ។



លោកគ្រូអាចារ្យដេត មានពុទ្ធដិកាមកកាន់ខ្ញុំថា :

- ឥលូវនេះកូនឯងនៅវត្តថ្មគោល រៀនអក្សរបន្តទៅទៀតសិនទៅ ព្រោះលោកគ្រូធំ លោកកំពុងតែរកដីសង់វត្តថ្មី។

ថ្ងៃខែចេះតែកន្លងហួសទៅ។ ការរស់នៅជាមួយគ្នារវាងលោកសង្ឃទាំងពីរគណៈ(អែវម៉ែ និងអេវម៉េ) ចេះតែមានសភាពតានតឹងឡើងជាលំដាប់។ យប់មួយនោះ លោកគ្រូអាចារ្យចៅខាងធម៌សម័យ លោកបាននិមន្តភិក្ខុ និងសាមណេរមកប្រជុំ។

- កាណា(លោកគ្រូធំមានពុទ្ធដិកា) និមន្តអស់លោកមកប្រជុំនៅពេលនេះ ដើម្បីទូលថា ឧបាសក ឧបាសិកាជើងវត្តទើបនឹងរកដីបានមួយដុំធំនៅជាប់បឹងកុកសំរាប់ធ្វើវត្ត។ ដូចនេះកាណាចាត់លោកគ្រូអាចារ្យគ្រីនិងអាចារ្យស្ទួង អោយនាំលោកភិក្ខុនិងនេនទៅរៀបចំកាប់ឆ្ការព្រៃទីនោះ រួចសង់កុដិជាបន្តបន្ទាប់។



# វត្តបឹងកុក

ធ្វើបុណ្យហូរហៀក្នុងវត្ត ដូចវេរភត្ត[៥]អោយឆ្កែ។

(ខ្មែរក្រហម)

នៅខាងលិចទីក្រុងកំពង់ចាម គេឃើញមានបន្ទាយទាហានដ៏ធំៗពីរសង់នៅជាប់គ្នា គឺបន្ទាយទាហានជើងក្រហម«canard osé pied rouge»[៦] និងបន្ទាយទាហានជើងខ្មៅ«canard osé pied noir»[៧]។ មេបញ្ជាការខាងទាហានជើងក្រហមជាបារាំង ចំណែកខាងជើងខ្មៅជាខ្មែរ។ បើខ្ញុំមិនច្រឡំទេ ជំនាន់នោះគឺលោក ក្លូត ប៊ុត ជាមេបញ្ជាការ។ ទាហានទាំងពីរក្រុមនេះឈ្លោះកាប់ចាក់គ្នាគ្មានស្វាង។ អភ័ព្វណាស់ ខ្មែរយើងមិនដែលចេះសាមគ្គីគ្នាម្ដងណាទេ តាំងតែពីដើមរហូតមក។ គ្រហស្ថឈ្លោះដោយគ្រហស្ថ បព្វជិតឈ្លោះទៅដោយបព្វជិត ចំណែកឯឆ្កែទៅដោយឆ្កែ។



នៅជាប់បន្ទាយជើងខ្មៅ គេឃើញមានបឹងមួយយ៉ាងធំ បឹងនោះគឺបឹងកុក។ នៅលើផ្ទៃបឹងដ៏ល្វឹងល្វើយ គេឃើញមានបឿនដុះពាសពេញ។ បឿនគឺជាការប្រជុំដោយតិណជាតិផ្សេងៗមានត្រកួន កញ្ឆែត ត្រាវ កក់ ច្រាច់ ត្រកៀត កំប្លោក-ល- ដែលដុះតាន់តាប់ ក្រាស់ឃ្មឹកអណ្ដែតលើទឹក ហើយដែលយើងអាចដើរជាន់ពីលើបាន។ ក្រោមបឿនមានឫសដុះស្លែ គឺជាជំរកនៃត្រីទាំងឡាយ។ ក្រៅពីជំរកនៃមច្ឆា បឹងកុកគឺជាអាងមួយយ៉ាងធំសំរាប់ទទួលទឹកសំអុយ ដែលគេបង្ហូរមកពីបន្ទាយទាហានជើងខ្មៅនិងជើងក្រហម។ ប្រសិនណាជាគ្មានទឹកថ្មីមកផ្លាស់ទឹកចាស់មួយឆ្នាំម្ដងៗទេនោះ ទឹកក្នុងបឹងនឹងក្លាយទៅជាទឹកសំអុយមិនខាន។ នៅរដូវវស្សា ទឹកក្នុងទន្លេមេគង្គឡើងយ៉ាងខ្លាំង ហើយហូរតំហុកចូលទៅក្នុងបឹង យកទឹកថ្មីទៅផ្លាស់ទឹកចាស់។

នៅខាងកើតបឹង គឺភូមិមេម៉ាយ ខាងលិចមានកន្លែងកប់ខ្មោចចិន និងដីទួលមួយយ៉ាងធំ។ ដីទួលនោះហើយ ដែលឧបាសក ឧបាសិកាខាងលោកគ្រូអាចារ្យថោប្រគេនទៅលោក ដើម្បីរៀបចំសង់វត្ត គឺវត្តបឹងកុកនោះឯង។ ដីទួលនោះធំទូលំទូលាយ តែមានស្មៅនិងដើមឈើដុះស៊ុបទ្រុបត្រូវប្រើពេលយូរណាស់ ដើម្បីកាប់ឆ្ការកូនឈើ។

ជំនាន់នោះ អ្នកដែលទៅតាមលោកគ្រូអាចារ្យគ្រី និងអាចារ្យសួងមានលោកសង្ឃ១០អង្គ សិស្សបីនាក់គឺខ្ញុំ អាឆៃ និងអាទិត។ បើគិតតាមលេខរៀង ខ្ញុំជាសិស្សលេខ១ នៅវត្តបឹងកុក។

រៀងរាល់ព្រឹកមុនពេលព្រះអាទិត្យរះ លោកគ្រូអាចារ្យគ្រីនិងអាចារ្យសួងតែងតែចាត់យើងទាំងបីនាក់ អោយទៅយកវេននៅផ្សារកំពង់ចាម ភូមិមេម៉ាយ ដីដុះ-ល-។

ព្រះសង្ឃធ្វើដងរែកពីឫស្សីអោយយើងមួយម្នាក់ៗ។ ដោយខ្ញុំតូចជាងគេ លោកអោយរែកតែចានស្រាក់ពី៤ទៅ៥តែប៉ុណ្ណោះ។ ចំណែក

អាឆៃ និងអាទិតពីលទៅផ។ មួយថ្ងៃៗ ពូតែវារអ៊ូ ព្រោះណាមួយវាធ្ងន់ ណាមួយវាឃ្លានបាយ ព្រោះពីព្រឹករហូតដល់ពេលលោកឆាន់បាយថ្ងៃត្រង់រួច ទើបបានបាយចូលពោះ។ ព្រលឹមស្រាងៗ មិនទាន់បាត់ងងុយដេកផង ពួកយើងត្រូវទៅបត់ជើងនៅមុខលោក ដើម្បីចាំទទួលបញ្ជា។

- អាឆៃ(លោកគ្រូអាចារ្យត្រីបញ្ជា) ឯងទៅយកវែននៅផ្ទះតាឈប់ អាទិតផ្ទះអ្នកស្រីតុប អាខៃផ្ទះអ្នកស្រីគង់។

កាលនោះ ខ្ញុំទៅយកវែនផ្ទះអ្នកស្រីគង់សឹងរាល់ថ្ងៃ។ គួរកត់សំគាល់ថាអ្នកស្រីគង់ជាម្តាយរបស់ខៀវ សំផន។ គាត់ជាមនុស្សជឿបុណ្យបាបណាស់។ គាត់ទៅសុំសីលរៀងរាល់ថ្ងៃសីល មិនសមបើបានកូនជាមេឃាតកររាស្ត្រខ្មែរសោះ។ នេះពិតជាសំណើចចំអកនៃព្រហ្មលិខិតមែន!

ថ្ងៃមួយនោះ ខ្ញុំទៅយកវែនជាមួយអាឆៃនៅផ្ទះអ្នកស្រីតុប ឯភូមិមេម៉ាយ។ ថ្ងៃត្រង់ហើយ ព្រះអាទិត្យបញ្ចេញចំហាយក្តៅយ៉ាងខ្លាំង ធ្វើអោយយើងបែកញើសជោកខ្លួន។ ភូមិមេម៉ាយមិនសូវមានផ្ទះប៉ុន្មានទេ ហើយផ្ទះនីមួយៗនៅដាច់ពីគ្នាឆ្ងាយណាស់។ សងខាងផ្លូវគឺដើមត្រែង។ អាឆៃ និងខ្ញុំរែកចានស្រាក់មកដល់កន្លែងស្ងាត់មួយ ស្រាប់តែខ្ញុំឃើញវាបើកគ្របចានស្រាក់។ ខ្ញុំមិនចាប់ភ្លឹក ព្រោះស្មានតែវាបើកមើលតាមធម្មតា ស្រាប់តែប៉ែ! អាឆៃលូកយកនំអាកោមួយមកពមផ្លប់ក្នុងមាត់ រួចហើយវាបើកចានស្រាក់មួយទៀត យកបាននំច័ក្កច័នមួយដុំទៀតមកស៊ីធ្វើវាហឺ។

- យីអាឆៃ(ខ្ញុំស្រែក) ឯងម៉េចបានជាហ៊ានស៊ីមុនលោកអ៊ីចឹង? ឯងមុខជាចុះនរក ឯងមុខជាទៅជាក្អែក។ អាក្អែក! អាក្អែក!...

- អាល្បល់យក៏ អញធ្វើតែអ៊ីចឹងតាំងពីដើមមក។ អាណាទ្រាំបានតាំងពីព្រលឹម រហូតលោកឆាន់បាយរួច ទើបបានស៊ីបាយនោះ។ អាទិតវាក៏ធ្វើដូចអញដែរ។ និយាយមិនទាន់បានចប់សព្វគ្រប់ផង អាឆៃបើក





គ្របចានស្រាក់មួយទៀត លូកយកនំអាកោមួយមកញាត់មាត់ខ្ញុំផ្លប់។ រួចហើយវាយកដៃវាមកបបោសមាត់ខ្ញុំថ្នមៗ ព្រោះមានកំទេចដូងជាប់មាត់។ ធម្មតាគេតែងកោសដូងដាក់លើបង្អែម ហើយចានស្រាក់ដាក់បង្អែមនៅពីលើគេជានិច្ច។

- អាភ្លើ(អាឆៃនិយាយ) អញបោសមាត់ឯង ព្រោះមានកំទេចដូង។ បើឯងយកកំទេចដូងនេះទៅកុដិ លោកគ្រូពិតជាវាយឯងស្លាប់ ព្រោះលោកដឹងថា ឯងលួចស៊ីនំ។

ចាប់តាំងពីអាឆៃបំបួសខ្ញុំមក ខ្ញុំចេះលួចស៊ីរហូត។ លួចស៊ីនៅភូមិមេម៉ាយ រួចបន្តទៀត ពេលមកដល់ត្រង់ផ្លូវខ្មោចចិន។ ដោយរកល្បិចនេះឃើញ ខ្ញុំមានកំលាំងរហូតឥតមានហេវហត់ដូចពីលើកមុនឡើយ។

បួនប្រាំខែក្រោយមក ព្រះសង្ឃក៏សង់បានកុដិបីបួន និងសាឡមមួយ (វិហារឈើបណ្តោះអាសន្ន)។ ព្រះសង្ឃវត្តថ្មគោលទាំងអស់ បូកទាំង

ក្មេងវត្ត ព្រមទាំងឆ្កែផង បាននិមន្ត និងនាំគ្នាមកនៅវត្តបឹងកុកជាស្ថាពរ។ ម្តងនេះ អស់មានសង្គ្រាជពីរទៀតហើយ។

ដោយគ្មានទឹកម៉ាស៊ីននិងអណ្តូង ព្រះសង្ឃនិងក្មេងវត្ត នាំគ្នាប្រើប្រាស់និងមុជទឹកបឹងកុក។ លុះមុជយូរៗទៅ ទាំងព្រះសង្ឃ ទាំងក្មេងវត្តកើតចៃចេញពីខ្លួនរៀងៗខ្លួន។ ចៃនោះខុសពីចៃចេញពីក្បាល គឺត្រង់វាមានពណ៌ស ចំណែកឯចៃក្បាល វាមានពណ៌ខ្មៅ។ ក្រៅពីកើតចៃ អាក្មេងវត្តធំៗ បែបព្រះសង្ឃផងមិនដឹង កើតស្រែងកង្កែបពេញពង ជាពិសេសអាឆៃ ដែលស្មោកគ្រោកជាងគេ។

ឆ្នាំ១៩៤៩...

ល្ងាចមួយនោះ លោកគ្រូធំកោះហៅក្មេងមកប្រជុំ :

- អាទិត(លោកគ្រូធំមានពុទ្ធដិកា) អាជួន អាជ្រឹង អញនឹងបំបួសឯងក្នុងពេលឆាប់ៗនេះ។ ចំណែកអាខៃ អាឆៃ អាម៉ែន អញអោយឯងទៅរៀនសាលាបារាំងនៅភូមិមេម៉ាយ ព្រោះឯងដូចជាឆ្លាតជាងគេខាងអក្សរនិងគណិតសាស្ត្រ។ ឆ្នាំនោះ ខ្ញុំចូលរៀននៅថ្នាក់បរិវច្ឆនដ្ឋាន។

ចាប់តាំងពីពេលនោះមក ក្មេងវត្តចែកចេញជាពីរពួក ក្មេងវត្តមួយផ្នែករៀនធម៌បួស មួយផ្នែកទៀតរៀនអក្សរបារាំង។

លុះរៀនដល់ថ្នាក់មជ្ឈិមដ្ឋានទី១(ឆ្នាំ១៩៥១) ស្រាប់តែខ្ញុំជក់ល្ខោន(ចេះតែចង់ទៅមើលល្ខោន)ថៅកែបាឡាត់អូន ដែលមានលោកសាំងសារុន ជាតួឯកដ៏ល្បីល្បាញនៅជំនាន់នោះ។

នៅវត្តបឹងកុក ខ្ញុំមានសំលាញ់ម្នាក់ទៀតឈ្មោះអាហន។ អាម្នាក់នេះជាក្មេងវត្ត ហើយចូលចិត្តមើលល្ខោនជាងខ្ញុំទៅទៀត។ រឿងព្រាយល្ខោនចូលលុកក្នុងខ្លួនខ្ញុំនេះ លោកគ្រូឥតដឹងទេ។ នៅពេលថ្ងៃលិចអាហននិងខ្ញុំនាំគ្នាដើរពីវត្តបឹងកុកទៅរោងល្ខោនបាឡាត់អូន ដែលនៅមិនឆ្ងាយប៉ុន្មានពីផ្សារកំពង់ចាម។





ពេលទៅមិនជាអីប៉ុន្មានទេ ព្រោះចង់មើលល្ខោននិងប្រញាប់អោយទាន់គេ«លោតម៉ាដាំ»[d] បើកឆាក។

លុះពេលត្រលប់មកកុដិវិញ យ៉ាប់តែម្តង ណាមួយងងុយដេក(ល្ខោនវាំរោងនៅពេលកណ្តាលអធ្រាត្រ) ណាមួយខ្លាចខ្មោច។

ពីរោងល្ខោនមកដល់បន្ទាយទាហានជើងខ្មៅ មិនជាអីទេ ព្រោះមានភ្លើងអគ្គិសនីភ្លឺព្រោងព្រាត។

ពីបន្ទាយទាហានជើងខ្មៅមកវត្តបឹងកុក បើសិនជាយប់ខែភ្លឺ ក៏វាមិនអីដែរ តែបើជារាត្រីនោចវិញ ម៉ែអើយ! ងងឹតចាក់ភ្នែកមិនយល់ គឺដើរស្ទាបតែម្តង ជួនកាលទង្គិចជើងនឹងថ្មដួលទឹងណាត់ទឹងណែង។ ៥០០ម៉ែត្រពីបន្ទាយ គឺកន្លែងកប់ខ្មោចចិន។ មកដល់ត្រង់ហ្នឹង អាហន

និងខ្ញុំភ្លេចអស់ហើយរឿងល្ខោនៗ យើងដើរបិទភ្នែក ហើយកាន់ដៃគ្នាទៅវិញទៅមក ព្រោះម្នាក់ៗមិនទុកចិត្តម្នាក់ ខ្លាចអាមួយរត់ចោលអាមួយនៅពេលខ្មោចចិនលងៗ

ផល់ជក់ល្ខោនយូរទៅ ខ្ញុំចាប់ចិត្តស្រលាញ់តួឯកល្ខោនមែនទែន ហើយមិនមែនស្រលាញ់លោកសាំង សារុនទេ គឺស្រលាញ់តួឯកស្រីដែលជាកូនចៅកែល្ខោនតែម្តងៗ ស្រលាញ់នោះមិនដឹងជាមានន័យថាដូចម្តេចទេៗ បើថាស្រលាញ់ចង់ទុកធ្វើជាអនាគត ក៏ថាមិនត្រូវ ព្រោះខ្លួនឯងនៅតូច ហើយមិនទាន់ចេះនូវរឿងស្នេហានៅឡើយៗ បើស្រលាញ់គេចង់ទុកធ្វើជាម៉ែ រឺទុកធ្វើជាបងស្រីវិញទើបត្រូវជាងៗ ពេលថ្ងៃព្រហស្បតិ៍ និងថ្ងៃអាទិត្យ ខ្ញុំនិងអាហានតែងតែដើរទៅរោងល្ខោនបាឡាត់អូន ចាំលបមើលតួឯកល្ខោននៅពេលថ្ងៃៗ លោកសាំង សារុនមានមាឌធំខ្ពស់ ស្គមកំព្រឹងៗ តែឮល្បីថា ប្រពន្ធនាម៉ឺនខ្លះរត់តាមគាត់ៗ





ចំណែកតួឯកស្រី កូនចៅកែល្ខោនក៏មិនសូវជាស្អាតប៉ុន្មានដែរៗ ខ្ញុំចេះតែនឹកក្នុងចិត្តថា ពួកហ្នឹងបែបមានព្រាយកាន់នៅពេលយប់ បានជាឃើញល្អតែពេលយប់ៗ

ពីរខែក្រោយមក ទើបលោកគ្រូដឹងថា ខ្ញុំជក់ល្ខោនឥតសូវបានរៀនសូត្រអីទេៗ លោកគ្រូខ្ញាល់នឹងខ្ញុំខ្លាំងណាស់ ហើយមានពុទ្ធដិកាមកកាន់ខ្ញុំថា :

- ពីថ្ងៃនេះទៅ បើឯងនៅតែលួចទៅមើលល្ខោនទៀត ឯងកុំមកជាន់កុដិគ្រូអោយសោះៗ

ចាប់តាំងពីថ្ងៃនោះមក ខ្ញុំឈប់ទៅមើលល្ខោនរហូតៗ

នៅរដូវវស្សា ពេលភ្លៀងធ្លាក់ជោកជាំ ការធ្វើដំណើរពីបន្ទាយដើងខ្មៅទៅវត្តបឹងកុកពិបាកណាស់ ពីព្រោះផ្លូវសុទ្ធតែភក់ ហើយជាប់ជើងដូចយើងពាក់ប្រូដឺកាំង(brodequin ជាស្បែកជើងក្រាស់ឃ្មឹក ដែលពួកទាហានខ្មែរជំនាន់បារាំងតែងពាក់) ព្រោះជាដីឥដ្ឋៗ បើជ្រុលតែដីភក់ជ្រៅបន្តិច ច្បាស់ជាលើកជើងលែងរួច ស្អិតជាងតាំងម៉ែរឺបាយម៉ានទៅទៀតៗ ដោយចង់ទាក់ទងអោយរាជការបារាំងធ្វើផ្លូវកៅស៊ូពីបន្ទាយជើងខ្មៅទៅវត្ត លោកគ្រូធំបែកប្រាជ្ញាសង់សាលាបារាំងពីរបន្ទប់នៅក្នុងវត្តៗ លុះសង់រួចរាល់ហើយ លោកក៏ប្រគល់សាលានោះទៅអោយក្រសួងសិក្សាធិការជាតិ ដោយសង្ឃឹមយ៉ាងមុតមាំថា រាជការពិតជាជួយធ្វើផ្លូវសំរាប់អោយសិស្សដើរបានស្រួលទៅកាន់សាលាៗ ដើម្បីសំរេចនូវគំរោងការនេះ លោកគ្រូបានចាត់អោយលោកគ្រូរឿង អតីតចៅហ្វាយស្រុកដែលចេះនិយាយភាសាបារាំងស្ទាត់ ទៅទាក់ទងនឹងមេសាធារណការជាតិបារាំងៗ គួរកត់សំគាល់ថា វត្តបឹងកុកមានអតីតរាជការចំណាស់ៗបីនាក់បានទៅសាងផ្នួស ព្រោះបើតាមព័ត៌មានថាលោកទាំងបីមានវិប្បដិសារីនៅក្នុងឆាកជីវិតៗ លោកសង្ឃទាំងបីអង្គ

នោះ គឺលោកតាប៊ុតដែលធ្លាប់ធ្វើគ្រូពេទ្យកាលនៅគ្រហស្ថ លោកតាស្បោងធ្វើតិញ្ញ និងលោកតារឿងអតីតចៅហ្វាយស្រុក។

ចៅហ្វាយស្រុករឿងកាលនៅធ្វើរាជការ លោកខិលណាស់ជាមួយនឹងស្រីៗ។ ប្រពន្ធរបស់លោក អ្នកស្រីតុប កើតទុក្ខរីងរៃ ដោយសារតែរោគប្រច័ណ្ឌ។ ថ្ងៃមួយនោះ អ្នកស្រីតុបមិននៅ លោកចៅហ្វាយស្រុកយើងយកសាហាយមកដេកលើផ្ទះ។ អ្នកស្រីតុបសម្ងំពួននៅក្នុងផ្ទះ រួចដេញទាន់ជាន់កែងលោកបាន។ ចាប់ពីថ្ងៃនោះមក លោកចៅហ្វាយស្រុកយើងរត់ចេញពីផ្ទះ ទៅចូលវត្តបឹងកុកទៅហោង។





មួយខែក្រោយពីលោកត្រូវរឿងបានទៅទាក់ទងជាមួយអាជ្ញាធរខាងសាធារណការមក គេឃើញមានត្រាក់ទ័រពីរមកឈូសផ្លូវ ពីបន្ទាយដើងខ្មៅទៅដល់សាលារៀនវត្តបឹងកុក។ សិស្សនិងគ្រូសប្បាយរីករាយជាខ្លាំង ព្រោះបានផ្លូវដើរមិនសូវជាប់ភក់។

សាលានោះមានពីរថ្នាក់ គឺមធ្យមដ្ឋានទី២«ក និង ខ» (cours moyen 2e année A et B) ដំបូលប្រក់ស្បូវ ជញ្ជាំងធ្វើអំពីដីឥដ្ឋលាយចំបើង អាចម៍គោនិងបន្ទះឫស្សី។ អាយុមិនបានមួយឆ្នាំផង សាលានេះទ្រុឌ-ទ្រោមចង់រលំទៅហើយ។ នៅតាមជញ្ជាំង គេឃើញបន្ទះឫស្សីលេច





ចេញពីដីឥដ្ឋអោយរពុយមិនខុសពីរនាំងព្រួលឡើយ។ ចំណែកនៅតាមសសរគេឃើញសុទ្ធតែហ្វូងកណ្ដៀរ។ បើមានខ្យល់ព្យុះធំ សាលានេះច្បាស់ជាបាក់សង្កត់ទាំងសិស្ស ទាំងគ្រូមិនខាន។

ឆ្នាំ១៩៥២ ខ្ញុំនិងអាឆៃត្រលប់ពីសាលាភូមិមេម៉ាយមករៀនឯសាលាបឹងកុកវិញ។ យើងទាំងពីរនាក់រៀននៅថ្នាក់មជ្ឈិមដ្ឋានទី២«ខ» ជាមួយគ្នា ហើយអង្គុយជាប់គ្នាថែមទៀត។ អាឆៃបងខ្ញុំយ៉ាងតិច៥ឆ្នាំ តែខ្ញុំហៅវាសឹងផាច់សាច់ តែវាមិនថាអីដែរ។ លោកគ្រូខ្ញុំ ឈ្មោះលោកគ្រូឆែប ចំណែកលោកគ្រូថ្នាក់មជ្ឈិមដ្ឋានទី២«ក» ឈ្មោះលោកគ្រូយក្ខ។ មែនទែន លោកគ្រូទាំងពីរមិនមែនឈ្មោះយក្ខ និងឆែបនោះទេ តែដោយម្នាក់មាឧធំ ម្នាក់ទៀតឆែបមាត់ ទើបសិស្សវាអោយឈ្មោះយក្ខនិងឆែបទៅ។ គាត់ទាំងពីរនាក់មិនដឹងទាល់តែសោះថា ឈ្មោះក្រៅរបស់គាត់គឺ



យក្ខនិងឆែប។ គ្រូទាំងពីរនាក់នេះកាចសាហាវណាស់ វាយសិស្សឥតត្រាប្រណី។ សិស្សម្នាក់ៗ មានរបួសទុកអោយកូនមើលគ្រប់ៗគ្នា។ ខ្ញុំរបួសដៃស្ដាំមានសំលាករហូតដល់សព្វថ្ងៃ។ នៅពេលឮសំលេងផ្ដៅខាងលោកគ្រូយក្ខ លោកគ្រូឆែបចាប់រករឿងសិស្សភ្លាម។ មួយថ្ងៃៗ ឮសូរតែសំលេងផ្ដៅឆ្លើយឆ្លងគ្នាដូចសំលេងដូរ្យតន្ត្រី។

នៅខាងលោកគ្រូឆែប សិស្សអាយុជិត២០ឆ្នាំមានប្រហែល១០នាក់។ លោកគ្រូឆែប និងយក្ខអោយសិស្សម្នាក់ៗ រកផ្ដៅអោយគាត់ម្នាក់មួយក្នុងមួយអាទិត្យ។ សិស្សណាមិនបានផ្ដៅត្រូវទោសយ៉ាងតិច១០រំពាត់។ បើកាលណាគេដើរចូលទៅក្នុងថ្នាក់ មុនដំបូងគេឃើញក្ដារខៀនពីរ រួចហើយរំពាត់ផ្ដៅមួយបាច់យ៉ាងធំនៅក្រោយក្ដារខៀន។ សិស្សម្នាក់ៗខ្លាចគ្រូជាងខ្លាចខ្លា តែពាក្យចាស់លោកថា : គ្រូកាច សិស្សខូច។ អាធំៗជំនុំគ្នាដើម្បីរកមធ្យោបាយទប់ទល់នឹងផ្ដៅដែលស្វិតពេក លោកគ្រូវាយវាមិនបាក់សោះ។ អាឃិន ក្បាលកញ្ចាស់ជាងគេ(អាយុប្រហែល២៣) អោយយោបល់ :

- បើតាមអញដឹង មានតែទឹកនោមទេទើបធ្វើអោយផ្ដៅស្រួយ។ ឯងទាំងអស់គ្នានាំគ្នានោមដាក់បំពង់ឫស្សី រួចហើយថ្ងៃព្រហស្បតិ៍ រឺអាទិត្យយើងយកទឹកនោមទៅស្រោចលើផ្ដៅ យកវាទៅហាលថ្ងៃ ផ្ដៅពិតជាស្រួយមិនខាន។

ចាប់តាំងពីពេលនោះមក គ្រូឆែបវាត់សិស្សមួយខ្វាប់ ផ្ដៅបាក់ប្រាវ! មួយខ្វាប់បាក់ប្រាវ! ក្នុងមួយថ្ងៃអស់ផ្ដៅមួយបាច់ធំ។ លុះដល់អស់ផ្ដៅគាត់ស្ទុះទៅកន្ត្រាក់បន្ទះឫស្សី ដែលលេចចេញពីជញ្ជាំងដីឥដ្ឋមកវាយសិស្សគ្មានត្រាប្រណី។ ម្ដងនោះមិនដឹងជាចៃដន្យអី នៅពេលដែលគាត់កន្ត្រាក់បន្ទះឫស្សីមកវាយសិស្ស ឫស្សីមុតដៃគាត់ចេញឈាមរ៉ាវ។ ឯសិស្ស បែបវាសប្បាយចិត្តពេកក៏មិនដឹង ស្រាប់តែផ្ទុះសំណើចគ្រប់គ្នា។

គ្រូឆែបមុខឡើងស្លាំង ចាប់វាយសិស្សបន្តទៅទៀតដូចឆ្កែឆ្កួត។ ដោយឃើញផ្តៅនោះចេះតែបាក់ ហើយបែបខ្លាចមុតដៃនឹងបន្ទះឫស្សីទៀត គ្រូឆែបដូរមធ្យោបាយដោយប្រើជន្លួញម្តង។ គាត់ចាក់សិស្សដូចចាក់គោ ជាពិសេសធ្វើបាបពួកអាធំៗ ព្រោះពួកវាស្ពឹក ហើយរៀនអន់ជាងអាតូចៗ។ លោកគ្រូឆែបវាយសិស្សខ្លាំងនៅពេលសរសេរតាមអានបារាំង(dictée française) ជាពិសេសគឺ accord du participe passé employé avec l'auxiliaire «avoir»។ នៅពេលសរសេរតាមអានម្តងៗ អាឆៃភ័យណាស់ មុខឡើងស្លាំង ព្រោះគ្រូចេះតែដើរមកខ្វិលៗពីក្រោយខ្នងវា។

នៅជំនាន់នោះ សិស្សប្រើស្លាបប៉ាកា ដែលមានដងធ្វើអំពីឈើ ហើយស្លាបវាធ្វើអំពីដែក។ សិស្សអាចដកស្លាបប៉ាកាផ្លាស់ប្តូរបាន នៅពេលដែលវាសឹក រឺចាស់គរិលពេក។ នៅលើតុសិស្ស គេឃើញមានដបទឹកខ្មៅម្នាក់មួយៗ។

បើនិយាយពីស្លាបប៉ាកាអាឆៃវិញ ឡើងក្រាំងដោយសារទឹកខ្មៅរុំព័ទ្ធ ហើយវាមិនដែលដូរសោះ។ ថ្ងៃមួយនោះ ជាថ្ងៃសរសេរតាមអានបារាំងអត្ថបទនោះ ខ្ញុំនៅចាំទាល់ឥលូវនេះ គឺវត្តនៅភូមិខ្ញុំ(la pagode de mon village)។ នៅពេលចាប់ផ្តើម លោកគ្រូឆែបមិនដឹងជាចៃដន្យអីគាត់មកច្រត់ដៃក្បែរអាឆៃ។ លោកគ្រូចាប់អាន សិស្សចាប់សរសេរ (entourée d'une importante haie de koki, la pagode laisse apercevoir de loin son toit de tuiles rouges)។ អាឆៃ ដោយវាភ័យនឹងជន្លួញលោកគ្រូឆែបពេក ស្រាប់តែនិយាយចេញខ្លួនឯង ដោយលោកគ្រូឥតទាន់សួរផងថា :

- បានជាគេសរសេរ«entourée» e accent-aigu e ពីព្រោះប្រធានវា(sujet) «la pagode»។ រួចហើយមិនដឹងជាវារញីរញ័រដូចម្តេចទេ





ស្រាប់តែវាយកស្លាបប៉ាកាទៅចាក់ដៃលោកគ្រូឆែប ដែលច្រត់នៅលើតុរបស់វាពួសួរឈឺប។ លោកគ្រូភ្ញាក់ផង និងបែបឈឺផង ស្រែកឮសូរអូយ! រត់ទៅអង្គុយចេញទឹកភ្នែកនៅមាត់ទ្វារថ្នាក់។ ថ្ងៃនោះ លោកគ្រូឆែបវាយអាឆៃទាល់តែរាកនោម។ តែចាប់ពីនោះមកដែរ អាឆៃបានសុខរហូត ព្រោះគ្រូឆែបបែបញញើតអាឆៃ មិនសូវហ៊ានមកក្បែរវាទៀតទេ។

ថ្ងៃមួយនោះជាថ្ងៃចន្ទ។ ក្រោយពីឮស្គរជួង សិស្សនាំគ្នាឈរជាពីរជួរនៅមុខថ្នាក់ ចាំស្តាប់បញ្ជាគ្រូ។ ក្រោយពីកូនសិស្សចូលថ្នាក់អង្គុយស្រួលបួលហើយ លោកគ្រូឆែបក៏ដើរទៅកាន់តុរបស់គាត់ ហើយដាក់គូទទៅលើកៅអីឈើយ៉ាងស្រួល។ គាត់បើកថតតុខ្វាក ស្រាប់តែរំពេចនោះ គាត់ផ្ទាវខ្លួនទៅក្រោយ ស្ទុះរត់ចេញពីតុយ៉ាងប្រញាប់ស្រែកទៅកាន់សិស្សថា :

- អាចង្រៃណាជុះអាចម៍ដាក់ថតតុ?

មុខគាត់ឡើងក្រហមដូចល័ខ។ គាត់ដេញសិស្សចេញពីថ្នាក់ ម្នាក់ៗមុខឡើងស្លាំង។

- តុណាត្រូវវេនបោសថ្នាក់ ថ្ងៃហ្នឹង?

- តុទីមួយ លោកគ្រូ(អាឃិនឆ្លើយ)។

- បើអីចឹង(លោកគ្រូបង្គាប់) ពួកអាតុទី១យកថតតុទៅលាង។

ចំជាស៊ីយមែន អាតុទី១គឺខ្ញុំនិងអាឆៃ។ ខ្ញុំនិងអាឆៃនាំគ្នាទៅសែងថតតុចេញទៅក្រៅ។ ម៉ែអើយ! អាចម៍អីក៏ស្អុយម្ល៉េះ ស្អុយខ្មោះតែម្តង គឺស្អុយជាងអាចម៍អាឆៃកាលវាលេចដាក់ខោ កាលពីវានៅវត្តថ្មគោលទៅទៀត។ អាចម៍នេះបានជាស្អុយប្លែក មកពីអាអ្នកជុះដាក់ថតតុ ជុះតាំងពីល្ងាចថ្ងៃសៅរ៍ម្ល៉េះ។ ដូចនេះ ល្មមដល់ថ្ងៃចន្ទ ពីរយប់មួយថ្ងៃឯណោះ។ ថ្ងៃនោះឯង មិនខុសពីថ្ងៃលេងសៀកទេ គឺអស់ពីវាយសិស្សនៅក្នុងថ្នាក់ហើយ គ្រូឆែបដេញសិស្សចេញពីថ្នាក់អោយទៅលុតជង្គង់នៅកណ្តាលថ្ងៃក្តៅទៀត។ គាត់ធ្វើបាបសិស្សចង់ស្លាប់ តែមួយអាទិត្យក្រោយមក គ្រូឆែបដូចស្លូតច្រើន។

ក្រោយមកខ្ញុំដឹងថា អ្នកដែលជុះអាចម៍ដាក់ថតតុគ្រូ គឺអាឆៃហ្នឹងតែម្តង ព្រោះវាសារភាពនៅពេលវិស្សមកាលធំបែកពីគ្រូឆែប។ ទេវតាមិនជួយ ត្រូវវានិងខ្ញុំលាងអាចម៍ស្អុយស្ទើរប្រកាច់។ ខ្ញុំប្រទេចផ្តាសាវាបីថ្ងៃបីយប់។

- «រើង» មិនអោយអញធ្វើអីចឹងម៉េចនឹងកើត(អាឆៃនិយាយមកកាន់ខ្ញុំ) បើគាត់សាហាវដូចខ្លាអីចឹងនោះ។





# ជំងឺស្នេហា

**អាឆៃជួបចាន់ធូជាគូព្រេង ខ្លួនខ្ញុំនៅក្មេងវង្វេងស្នេហ៍។**

លុះរៀនដល់ថ្នាក់ឧត្តមដ្ឋាន អាឆៃមានអាកប្បកិរិយាផ្លាស់ប្តូរច្រើនណាស់។ ព្រះសង្ឃក៏លែងអោយវាទៅយកវេននៅថ្ងៃព្រហស្បតិ៍ រឺអាទិត្យ ព្រោះលោកយល់ថាវាធំណាស់ទៅហើយ។ មួយថ្ងៃៗ ខ្ញុំឃើញវាឆ្លុះកញ្ចក់ ផ្ទៀងផ្ទងមើលផងខ្លួន និងសិតសក់យ៉ាងតិច២០លើក។ វាសិតសក់«បូកគោ» (ជាម៉ូតជំនាន់នោះ) រុញឡើងទៅលើកំប៉ូកៗ ដូចបូកគោ ហើយយកប្រេងប្រ៊ីយ៉ង់ទីន(brillantine) មកលាបសក់ កុំអោយវារសាត់ រឺធ្លាក់មករប៉ាត់រប៉ាយ។

ថ្ងៃមួយនោះ វាទៅនិយាយប្រាប់ម៉ែឪវាថា វាជិតប្រឡងចូលវិទ្យាល័យហើយ ហើយគ្រូបង្គាប់អោយទិញកង់«គួក» (course) ខោបារាំងព្រមទាំងស្បែកជើង«អង់ប្រង់» (តាមពិតគឺ«en France») តែខ្មែរយើង

*អានមិនច្បាស់ នាំគ្នាថា«អង់ប្រង់ៗ» ទៅ។ ដោយសារចាញ់ប្រូអាឆៃ ម៉ែឪវាទៅលក់ស្រែអំពក(ស្រែតូចៗ) អស់ពីរបី ដើម្បីទិញរបស់ខាងលើអោយវា។ គួរអោយអាណិតអាសូរម៉ែឪអាឆៃណាស់ ហេតុតែគាត់ចង់អោយកូនចូលវិទ្យាល័យ ក្រែងបានធ្វើចៅហ្វាយខេត្ត... ចុងគ្រាន់នឹងបានស៊ីសំណូកដូចគេ ព្រោះធ្វើស្រែវានឿយពេក។*

*ពេលវេលាចេះតែកន្លងទៅជាលំដាប់ អាឆៃកាន់តែមានចិត្តរវើរវាយខ្លាំងឡើងៗ។ ល្ងាចមួយនោះ ខ្ញុំឃើញវាដេញម៉ង់ដូលីន(mandoline) នៅលើកុដិ ពីព្រោះលោកគ្រូធំនិងភិក្ខុឯទៀតនិមន្តទៅសូត្រមន្តឯភូមិមេម៉ាយ សល់តែលោកទិតនៅចាំកុដិ។ ទិត ឆៃ ខៃ សុទ្ធតែមិត្តភក្តិជិតដិត ខុសតែទិតទៅជាតំណាងព្រះពុទ្ធប៉ុណ្ណោះ។ ប៉ុន្តែយើងទាំងបីនាក់នៅតែលេចលើស្មើក្រោមនឹងគ្នាដដែល។ អាឆៃជាអ្នកដេញម៉ង់ដូលីន លោកទិតជាអ្នកច្រៀង : «ឱផ្កាណាគ្រីកស្គុះស្គាយ...» បន្ទាប់មកទៀត : «ព្រះពាយផាយផាត់ បក់កាត់ឆ្លងមក យប់ជ្រៅ ចុងស្រល់អែនទៅ អែនទោរទន់តាម ខ្យល់បោក...» ចុងទីបញ្ចប់គឺបទផ្កាខ្មៅ : «យប់មិញខ្ញុំ*





*គេងលក់ទៅ ក្នុងពេលយប់ជ្រៅ...»។ ជំនាន់នោះ បទផ្កាខ្មៅ ផ្កាណាគ្រីនិងចុងស្រល់ ជាបទដែលគេនិយមនៅគ្រប់ទីកន្លែងក្នុងស្រុកខ្មែរ។*

*ក្រោយពីច្រៀងហើយ បែបហត់ក៏មិនដឹង លោកទិតប្រើអោយខ្ញុំទៅយកកំសៀវទឹកដែលលោកដាំទុកមួយស្របក់ធំហើយ។ នៅពេលដែលខ្ញុំយកកំសៀវទឹកមកដល់ លោកទិតស្ទុះទៅយកចានស្លាបព្រា។ មុនដំបូងខ្ញុំឆ្ងល់យ៉ាងខ្លាំងថា ហេតុម្តេចបានជាលោកទិតស្ទុះទៅយកចានស្លាបព្រាមិនយកកែវមកវិញ។ លោកទិតចាក់ទឹកកំសៀវទៅក្នុងចានតែទឹកមានពណ៌ស ហើយហុយឃីតៗ ហាក់ដូចជាយើងស្ទះនោម។ លោកទិតបើកគំរបកំសៀវខ្វាក។ ពេលនោះទើបខ្ញុំដឹងថា លោកទិតមិនមែនដាំទឹកតែទេ គឺដាំបបរ។ ខ្ញុំស្រែកឡូឡា :*

*- យីលោកទិត ម៉េចក៏ដាំបបរអ៊ីចឹង... លោកសង្ឃណាឆាន់បបរពេលយប់។ ចាំមើល កាណាទូលលោកគ្រូធំហើយ។*

*- ឯងមិនអោយអញស៊ីយ៉ាងម៉េច បើអញឃ្លានចង់ស្លាប់ទៅហើយ។*

*អាឆៃមានហិបឈើមួយយ៉ាងធំ សំរាប់ដាក់ខោអាវនិងសៀវភៅ។ ថ្ងៃមួយមិនដឹងជាចៃដន្យអី អាឆៃវាភ្លេចបិទហិប ខ្ញុំក្រឡេកទៅក្នុងហិបឃើញសំបុត្រមួយគំនរ។ ខ្ញុំរពឹសដៃ ក៏ស្ទុះទៅយកសំបុត្រទាំងនោះមកមើល។ ប៉េ! គឺសុទ្ធតែសំបុត្រស្នេហា ដែលអាឆៃសរសេរទុកជាយូរខែណាស់មកហើយ ហើយមិនចេះបានផ្ញើសោះ។ សំបុត្រទាំងអស់នោះប្រហែល១០។ ខ្ញុំបើកសំបុត្រទីមួយមើល :*

***«មកដល់អូនចាន់ធូ!***

***ជាបឋមសូមអូនអភ័យទោស ព្រោះតាំងពីបងបានឃើញនិងស្គាល់អូនមក បេះដូងរបស់បងដើរខុសចង្វាក់រៀងរាល់ថ្ងៃ...***

***ហត្ថលេខា***

***ហុង វ៉ាន់ឆៃ»***

*ខ្ញុំយកសំបុត្រទី២ មកមើលទៀត :*

***«...ម្ចាស់ស្នេហ៍បងអើយ បើបងមិនបានឃើញដំបូលផ្ទះអូនទេ បងពិតជាបាយមិនបាន អើងមិនលក់ៗ សូមអូនមេត្តាបងផង...»***

*ខ្ញុំអានទាល់តែអស់សំបុត្រអាឆៃ អានផងសើចផង សើចស្ទើរចុកពោះ ព្រោះសេចក្ដីក្នុងសំបុត្រមើលទៅ ពិតជាទប់សំណើចមិនបានឡើយៗ នៅពេលខ្ញុំអានសំបុត្រចប់ អាឆៃមកដល់ល្មមៗ*

*- យីអាខៃ អា«ល្បល់យក៏» ម៉េចលួចមើលសំបុត្រអញអីចឹង?*

*- អាឆៃ ឯងចាំបាច់លាក់នឹងអញធ្វើអី គ្រាន់តែរឿងស្នេហាអីចឹងនោះៗ ម៉េចឯងសរសេរសំបុត្រទុកមួយគំនរ មិនព្រមផ្ញើ?*

*- មកពីអញ(អាឆៃតប) មើលទៅដូចជាមិនពីរោះសោះអ៉ាៗ*

*- បើអីចឹងចាំអញជួយសរសេរម្ដងៗ អញសរសេរជាកំណាព្យវិញៗ*

*- មែនអ៉ា(អាឆៃនិយាយ) យោបល់ឯងល្អ ព្រោះឯងពូកែជាងអញឆ្ងាយណាស់ខាងតែងសេចក្ដី និងកំណាព្យកាព្យឃ្លោងៗ*

*ខ្ញុំចាប់ផ្ដើម :*

***«មកដល់អូនចាន់ធូម្ចាស់ស្នេហ៍ អូនអើយខ្លួនបងដូចទន្សាយភ្លើ ដែលចង់បានចន្ទនៅស្ថានលើ ល្ងីល្ងើម្នាក់ឯង កណ្ដោចិត្ត...***

***ហត្ថលេខា***

***ហុង វ៉ាន់ឆៃ***

***បុរសកំសត់»***

*អាឆៃយកកំណាព្យខ្ញុំមកអានបីបួនដងៗ វាសរសើរខ្ញុំមិនដាច់ពីមាត់*

*- ល្អមែនៗ អញពិតជាផ្ញើទៅនាងហើយ ម្ដងហ្នឹង!*

*ជីតាអាឆៃឈ្មោះហុងៗ នៅសាលាឈ្មោះវាពិតប្រាកដគឺ ហុង វ៉ាន់ឆៃៗ ឈ្មោះសំលាញ់ខ្ញុំពីរោះណាស់ សមតែឈ្មោះតូងកកុនៗ ដោយសារតែអាឆៃកើតរោគស្នេហា អីចឹងហើយបានជាវាទៅបោកម៉ែ*



*ឪវាអោយគាត់ទិញកង់ ខោអាវ ស្បែកជើង ហើយមួយថ្ងៃៗផ្សៀងផ្លុងៗនៅតែមុខកញ្ចក់ៗ វាខំរៀនដេញម៉ង់ដូលីនដើម្បីបណ្ដែតអារម្មណ៍ទៅតាមចង្វាក់ភ្លេងៗ*

*នាងចាន់ធូរៀននៅថ្នាក់មធ្យមដ្ឋានទី២ ជាកូនថៅកែរ៉ឺម៉កនៅក្បែរបន្ទាយជើងខ្មៅៗ អាឆៃស្គាល់នាង ដោយសារវាធ្លាប់ទៅយកវេននៅផ្ទះនាងជាញឹកញាប់ណាស់ៗ ឪពុកនាងឈ្មោះតន ម្ដាយឈ្មោះឈនៗ ថៅកែស្រីនេះឆ្នាសដូចអង្រ្កងភ្លើងៗ ថៅកែតនខ្លាចប្រពន្ធជាងខ្លាចម៉ែឪគាត់ទៅទៀតៗ នាងចាន់ធូមានបងប្រុសម្នាក់រៀនថ្នាក់ទី៥ នៅវិទ្យាល័យព្រះសីហនុជាប់នឹងបន្ទាយជើងក្រហមៗ*

*នៅពេលទៅយកវេននៅផ្ទះថៅកែតនម្ដងៗ អាឆៃតែងតែជួយជួសជុលរ៉ឺម៉កគាត់ៗ ថៅកែឃើងគាត់ពេញចិត្តនឹងអាឆៃណាស់ ព្រោះវាពូកែខាងជួសជុលម៉ាស៊ីន ហើយឆាប់យល់ការទៀតៗ នាងចាន់ធូស្គាល់អាឆៃច្បាស់ណាស់ ព្រោះជួនកាលថៅកែតនឃាត់វាអោយនៅស៊ីបាយជាមួយគាត់ ក្រោយពីជួសជុលរ៉ឺម៉កហើយៗ រាល់ថ្ងៃអាទិត្យ រឺថ្ងៃបុណ្យវាតែងតែដើរទៅក្រវែលផ្ទះនាងចាន់ធូ មិនខុសពីចោរដើរក្រឡឹងមើលផ្ទះនរណាម្នាក់ មុននឹងចូលទៅលួចនៅពេលរាត្រីៗ*

*យប់មួយនោះ ខែភ្លឺថ្លាល្អណាស់ៗ អាឆៃចេញបាត់ពីកុដិ ខ្ញុំចេះតែសួរខ្លួនឯងថា តើអាឆៃវាទៅណា? បន្តិចក្រោយមក ស្រាប់តែឃើញវាលេចមកដល់កុដិ ដកដង្ហើមស្ទើរមិនដល់គ្នា យួរស្បែកជើងម្ខាងនៅដៃស្ដាំៗ ខ្ញុំក៏សួរវា :*

*- វាម្ដេចទៅហើយ អាឆៃ?*

*- អាសំលាញ់អើយ! អញវិសតែកុនទៅហើយ ព្រោះបងនាងចាន់ធូដេញអញប្រកិតៗៗ*

*- បើអីចឹងមានតែឯងទៅលបនាង?*



- អញមិនមែនទៅលបនាងទេ អញទៅជួបនាង ព្រោះនាងអោយអញទៅជួប តែវាសិយដោយបងនាងឃើញ។

- រួចចុះស្បែកជើងមួយចំហៀងទៀត ទៅឯណាទៅ? (ខ្ញុំសួរ)។

- មិនដឹងជាជ្រុះនៅត្រង់កន្លែងណាទេ ព្រោះអញរត់ប្រាសអាយុយករួចខ្លួនមួយគ្រាសិន។

ជំងឺស្នេហាអាឆៃបានឆ្លងដល់ក្មេងៗសាលាបារាំងសឹងតែគ្រប់គ្នានៅក្នុងវត្តបឹងកុក មិនខុសពីជំងឺអាសន្នរោគ។ ពួកអាធំៗរៀននៅថ្នាក់ទី៦ មួយថ្ងៃៗគិតតែពីតែងខ្លួនសរសេរសំបុត្រស្នេហាផ្ញើទៅក្មេងស្រីរៀននៅថ្នាក់ឧត្តមផ្ដាន រឺរៀននៅវិទ្យាល័យជាមួយគ្នា។ ជំងឺស្នេហានេះក៏ស្រាប់តែឆ្លងមកដល់ខ្ញុំដែរ។ ជំនាន់នោះ ខ្ញុំអាយុ១៣ឆ្នាំ រៀននៅថ្នាក់ឧត្តមផ្ដាន(ឆ្នាំ១៩៥៣)។ ខ្ញុំក៏ក្លាយទៅជាក្មេងរវើរវាយ និងមានចិត្តងប់ងល់លន្លង់លន្លោចមិនខុសពីរ៉ឺណេ(René) តួអង្គមួយរបស់សាតូប្រឺយ៉ង់(Chateaubriand) អ្នកនិពន្ធជាតិបារាំងដ៏ល្បីល្បាញម្នាក់ ខាងផ្នែក«រ៉ូម៉ង់ទីស្សមណ៍(romantisme)» នៅសតវត្សទី១៩។ អ្នកនិពន្ធនេះ បានជះឥទ្ធិពលមកលើខ្ញុំខ្លាំងណាស់ ចាប់តាំងពីខ្ញុំរៀននៅថ្នាក់ទី៦ រហូតដល់សព្វថ្ងៃនេះ។ ខ្ញុំជាមនុស្សម្នាក់ដែលស្រលាញ់ធម្មជាតិ ទន្លេ បឹងបួ ព្រៃព្រឹក្សាលតាវល្លិ៍ ស្រលាញ់តាំងពីខ្ទមអ្នកតា រហូតដល់វិហារលោក។ ពេលជាប់អាពត



ខ្ញុំហាក់ដូចជាគ្មានពោះវៀនពោះតាំង ក្នុងខ្លួនរបស់ខ្ញុំគឺប្រហោងធ្លុង ព្រោះអ្វីៗដែលខ្ញុំស្រលាញ់ត្រូវខ្មែរក្រហមកំទេចចោលអស់រលីង។

ខ្ញុំនៅក្មេងសោះតែចង់បានសង្សារ តើខ្ញុំយកសង្សារមកធ្វើអ្វី? ខ្ញុំឥតសូវដឹងដែរ។ ខ្ញុំគ្រាន់តែដឹងថា ម្ដងនេះបើខ្ញុំមានគូកំណាន់ ខ្ញុំស្រលាញ់នាងខុសពីតួឯកល្ខោនតែប៉ុណ្ណោះ។

នៅក្នុងថ្នាក់ ក្រៅពីអាឆៃ ខ្ញុំមានពួកម៉ាកដ៏ជិតដិតម្នាក់ទៀតឈ្មោះអាម៉េង។ អាម៉េងអាយុច្រើនជាងខ្ញុំ។ វាជាកូនចិនលក់បាយនៅញ៉ាបផ្សារថ្មី កំពង់ចាម។ អាម៉េងភ្នែកអៀស៊ី។ សឹងតែរៀងរាល់ថ្ងៃ អាម៉េងតែងតែហៅខ្ញុំទៅស៊ីបាយនៅតូបលក់បាយរបស់ឪពុកវា។ កាលនោះក្មេងរៀនពីរពេល ព្រឹកពីម៉ោង៧ទៅដល់ម៉ោង១១ ហើយថ្ងៃពីម៉ោង១៤ដល់ម៉ោង១៧។ ដោយសារបានបាយសម្លឪម៉ែអាម៉េង ខ្ញុំមានកំលាំងរៀនសូត្រគ្រាន់បើ ពីព្រោះបាយវត្តមិនគ្រប់គ្រាន់ទេ ជួនកាលបាយជាមួយផ្អក ប្រហុក សៀង ទឹកត្រី រឺអំបិលបុកនឹងក្ដិបអំពិល។ ឪពុកម្ដាយរបស់សំលាញ់ខ្ញុំចិត្តល្អណាស់ បើមិនឃើញខ្ញុំទៅបាយថ្ងៃ គាត់តែងតែសួររកខ្ញុំជានិច្ច ជួនកាលនៅថ្ងៃព្រហស្បតិ៍ និងថ្ងៃអាទិត្យ ខ្ញុំទៅជួយលក់បាយគាត់ថែមទៀត។

អាម៉េងមានប្អូនស្រីម្នាក់ឈ្មោះអាមួយហ៊ាង។ អាមួយហ៊ាងរៀននៅសាលារៀនចិន អាយុស្មើនឹងខ្ញុំ។ អាមួយហ៊ាងធ្លាប់រៀននៅសាលាបារាំងដល់ថ្នាក់បរិវច្ឆនផ្ដាន រួចទើបឪពុកម្ដាយអោយទៅរៀននៅឯសាលាចិនវិញ។ ជំនាន់នោះ នាងក៏ជំទង់ ខ្ញុំក៏ជំទង់។ អាមួយហ៊ាង អៀឥតស៊ីភ្នែកដូចអាម៉េងទេ តែនាងមានភ្នែកតឹង។ នៅពេលសើចម្ដងៗភ្នែកលិបបាត់អស់។ មុនដំបូងខ្ញុំឥតមានចិត្តទៅលើនាងទេ តែលុះនៅជិតគ្នាយូរៗទៅ ស្រាប់តែខ្ញុំចាប់ចិត្តទៅលើនាង។ ខ្ញុំស្រលាញ់អាមួយហ៊ាង តែរឿងនាងស្រលាញ់ខ្ញុំវិញនោះ ខ្ញុំឥតដឹងទេ ព្រោះនាងឥតដែល



បញ្ចេញមនោសញ្ចេតនាបន្តិចសោះ។ មើលទៅបែបនាងមិនទាន់ចេះស្នេហាផងក៏មិនដឹង វាឡប់ៗតែខ្លួនខ្ញុំ។ អាម៉េងពេលវាឃើញខ្ញុំនិយាយជាមួយប្អូនរបស់វា វាតែងគេចរហូត ហាក់ដូចជាចង់អោយខ្ញុំនិងអាមួយហ៊ាងសាសងគ្នាតែពីរនាក់។ អាមួយហ៊ាង ហៅខ្ញុំថាហ៊ាៗ ជាភាសាចិន ខ្ញុំហៅនាងចំឈ្មោះ។ ខ្ញុំតំណាលរឿងរវើរវាយនេះប្រាប់អាហន មេជក់ល្បែន។ អាហនវាចេះតែជំរុញខ្ញុំអោយសារភាពប្រាប់អាមួយហ៊ាង តែខ្ញុំមិនហ៊ាន។ ថ្ងៃមួយ ខ្ញុំនិយាយទៅកាន់អាហន :

- អាហន! ធ្វើម៉េចទៅទើបអោយអាមួយហ៊ាងយល់សប្តិឃើញថាអញស្រលាញ់នាង អ្ហា?

- អញឮចាស់ៗគាត់ថា បើនរណាម្នាក់ចង់អោយនរណាម្នាក់ទៀតយល់សប្តិដឹងពីមនោសញ្ចេតនារបស់ខ្លួន សាមីខ្លួន នៅពេលកណ្តាល



អធ្រាត្រ ត្រូវក្រោកត្រលប់កន្ទេលពីម្ខាងទៅម្ខាង ឧទ្ទិសបំណងរបស់ខ្លួនទៅកាន់អ្នកដែលយើងចង់អោយគេដឹងពីទឹកចិត្តរបស់យើង។

ដោយខ្ញុំឡប់កាន់តែខ្លាំង ខ្ញុំក៏ធ្វើតាមអាហនមែន។ កណ្តាលអធ្រាត្រស្ងាត់ ខ្ញុំក្រោកត្រលប់កន្ទេល ហើយនិយាយម្នាក់ឯងដូចមនុស្សឆ្កួត «សូមអោយអាមួយហ៊ាងយល់សប្តិឃើញខ្ញុំស្រលាញ់នាង»។ លុះដល់ព្រលឹមឡើង ខ្ញុំក៏និយាយរឿងខ្ញុំប្រាប់អាហន។ អាហន វាអោយយោបល់ខ្ញុំថា :

- បើឯងទៅស៊ីបាយផ្ទះអាម៉េង ឯងលបមើលអាមួយហ៊ាងមើល បើនាងរាងអៀនៗ នាងពិតជាយល់សប្តិឃើញឯងស្រលាញ់នាងហើយ។

លុះដល់ខ្ញុំទៅផ្ទះនាង ខ្ញុំលបសង្កេតមើលអាកប្បកិរិយានាងមួយថ្ងៃទាល់ល្ងាច ឥតមានឃើញការផ្លាស់ប្តូរអ្វីសោះ។ កាលពីដើមយ៉ាងម៉េចមកដល់ឥលូវហ្នឹងវានៅតែដដែល។ ខ្ញុំអស់សង្ឃឹមតែម្តង។

នៅតែមួយខែទៀតទេ ខ្ញុំត្រូវប្រលងយកវិញ្ញាបនប័ត្របឋមសិក្សា។ ខ្ញុំមិនសូវបានទៅផ្ទះអាម៉េងទេ ព្រោះរវល់តែខំប្រឹងរៀនសូត្រ។ ក្រោយពីប្រលងជាប់វិញ្ញាបនប័ត្រួចហើយ ខ្ញុំក៏ប្រលងជាប់ចូលរៀនថ្នាក់ទី៦ទៀត។ ខ្ញុំសប្បាយចិត្តអស្ចារ្យនឹកថា ម្តងនេះអាមួយហ៊ាងប្រហែលជាស្រលាញ់ខ្ញុំហើយ។ ចំណែកអាម៉េង ក៏ប្រលងជាប់ដែរ។

ថ្ងៃនោះ អាម៉េងហៅខ្ញុំទៅផ្ទះវាតែម្តង។ ឪពុកវាក្តី អាមួយហ៊ាងក្តីបញ្ចេញនូវការសប្បាយរីករាយដោយសុទ្ធចិត្តចំពោះលទ្ធផលដ៏ល្អនៃយើងទាំងពីរនាក់។ នៅពេលត្រលប់ទៅវត្តវិញ អាមួយហ៊ាងលួចហុចសំបុត្រមួយអោយខ្ញុំ។ ខ្ញុំទទួលយកសំបុត្រពីនាង ដៃឡើងញ័រដូចស្គន់ជាន់។ ខ្ញុំដើរកាត់ថ្នល់មុខផ្សារត្រើ វិះជលរ៉ឺម៉ក។ លុះឆ្លងដល់ចិញ្ចើមថ្នល់ម្ខាងហើយ ខ្ញុំហែកសំបុត្រមើលភ្លាម។ ខ្ញុំនឹកសង្ឃឹមថាច្បាស់ជាមានសំបុត្រសារភាពពីរឿងស្នេហា តែផ្ទុយទៅវិញ ខ្ញុំខកចិត្តវិះដួល



ផ្កាប់មុខ ដោយឃើញលុយ៥០រៀលថ្មីស្រឡាងនិងកូនសំបុត្រតូចមួយ ដែលសរសេរថា«សូមហ៊ាយកលុយនេះសំរាប់ទិញសៀវភៅរៀន»។

ខ្ញុំអស់សង្ឃឹមតែម្តង ព្រោះខ្ញុំឥតចង់បានលុយទេ ខ្ញុំចង់បានតែចិត្ត។ ខ្ញុំចេះតែនិយាយម្នាក់ឯង«អញបែបឆ្កួតទេ រឺអី? រវើរវាយ ឡប់ៗតែម្នាក់ឯង។ អាក្បាលកញ្ជាស់អស់ហ្នឹង វាបង្រៀនអោយអញចេះស្នេហាមុនអាយុហើយមើលទៅ!»។

វិស្សមកាលធំ រឺវ៉ាកងធំមានរយៈពេលពីរខែ។ ខ្ញុំត្រលប់ទៅផ្ទះ តែខ្ញុំមិនជិះទូកដបណ្តោយទៀតទេ។ ម្តងនេះខ្ញុំដើរម្តង។ ខ្ញុំត្រូវទៅឆ្លងទូកដទទឹង(ទូកដឆ្លងកាត់ទន្លេពីត្រើយម្ខាងទៅត្រើយម្ខាង) នៅឯកៀនស្វែជ។ ពីទីក្រុងកំពង់ចាមទៅកៀនស្វែជ មានប្រហែល២៥គម។ លើកនេះ ខ្ញុំ



ឥតស្តាយកំប្រោងផ្តៅទេ ខ្ញុំស្តាយកាតាបកញ្ជាស់មួយដែលពោរពេញទៅដោយសៀវភៅខ្មែរនិងបារាំង។

ខ្ញុំដើរតាមមាត់ទន្លេមេគង្គ ស្រូបយកខ្យល់ទន្លេពេញៗសួត។ ដំណើររបស់ខ្ញុំមិនខុសពីដំណើរដោយជើងរបស់អ្នកនិពន្ធបារាំងម្នាក់ឈ្មោះ Jean-Jacques Rousseau[៥]នោះទេ។

បើខុសគ្នា ត្រង់គាត់ដើរនៅស្រុកបារាំង ខ្ញុំដើរនៅស្រុកខ្មែរ គាត់ដើរបេះផ្កាស្មៅយកមកទុក ខ្ញុំដើរបេះផ្លែអំពិលទឹក ត្រសក់ទុំ ខ្នុរទុំតាមផ្លូវ រឺតាមចំការយកមកបរិភោគ។

ទៅដល់កៀនស្វែជ មុននឹងឆ្លងទូកដទទឹងទៅកោះសំរោង ខ្ញុំចូលទៅសម្រាកក្នុងខ្ទមអ្នកតាមួយដែលសង់អំពីថ្ម នៅប្របព្រែកកៀនស្វែជ។ ខ្ញុំយកក្រូចពោធិ៍សាត់ពីរទៅថ្វាយអ្នកតា ដើម្បីសុំពឹងពាក់អ្នកតាអោយទៅពន្យល់សប្តិអាមួយហ៊ាងថា ខ្ញុំស្រលាញ់នាង។

ពីរខែកន្លងទៅ ថ្ងៃចូលរៀនមកដល់។ ខ្ញុំជិះទូកបណ្តោយត្រលប់ទៅវត្តបឹងកុក តែមុននឹងទៅវត្ត ខ្ញុំឆៀងចូលតូបលក់បាយឪពុកអាម៉េង។

បេះដូងខ្ញុំលោកក្តុកក្តាក់នឹកថា មុខជាបានជួបអាមួយហ៊ាង។ ខ្ញុំខកចិត្តជាខ្លាំងព្រោះអ្នកលក់បាយជាមនុស្សថ្មី។ គេបានប្រាប់ខ្ញុំថា ឪពុកម្តាយអាម៉េងឈប់នៅកំពង់ចាមហើយ។ គាត់ទៅរកស៊ីនៅឯភ្នំពេញតាំងពីមួយខែមុនម្ល៉េះ។ ខ្ញុំអស់សង្ឃឹមដើរទៅវត្តស្ទើរលើកជើងមិនរួច។

ប្រាំពីរឆ្នាំក្រោយមក គឺនៅឆ្នាំ១៩៦១ ខ្ញុំរៀននៅថ្នាក់ទីបញ្ចប់ឯវិទ្យាល័យស៊ីសុវត្ថិ។ ថ្ងៃមួយនោះ ជាថ្ងៃចូលឆ្នាំចិន។ ខ្ញុំកំពុងតែមើលកូនចិនលោតម៉ុងសាយនៅផ្សារកណ្តាល ស្រាប់តែជួបនឹងអាម៉េងដោយចៃដន្យ។ វាស្ទុះមកអោបរឹតខ្ញុំ ដោយបញ្ចេញនូវសេចក្តីសប្បាយរីករាយឥតឧបមា។ អាម៉េងនាំខ្ញុំទៅជួបឪពុកម្តាយវានៅឯផ្សារថ្មី។ ម្តងនេះគាត់លែងលក់បាយទៀតហើយ។ គាត់មានហាងមាសមួយយ៉ាងធំនៅ

ក្បែររោងកុនហាវ៉ៃ។ នៅពេលឃើញខ្ញុំ គាត់ទៅជាស្រឡាំងកាំង។ ចំណែកអាមួយហ៊ាង ដែលឈរនៅក្បែរនោះដែរ ស្រាប់តែមុខឡើងស្លេក ទឹកភ្នែករលីងរលោង ហើយឈរធ្មឹងដូចរូបចំលាក់។ តែនាងបានក្លាយទៅជាមាតានៃកូនក្មេងស្រីម្នាក់ទៅហើយ។ ខ្ញុំស្ទុះទៅលើកពរកូនអាមួយហ៊ាងដាក់នៅលើដើមទ្រូង ហើយអង្អែលខ្នងវាថ្នមៗ។

ឪពុកម្តាយអាម៉េងឃាត់ខ្ញុំអោយនៅញ៉ាំបាយល្ងាចជាមួយគាត់។ មុននឹងលាគាត់ទៅផ្ទះវិញ អាមួយហ៊ាងលួចហុចកូនសំបុត្រមួយមកខ្ញុំ។ ខ្ញុំទទួលសំបុត្រដាក់ក្នុងហោប៉ៅអាវ។ តែម្តងនេះខ្ញុំឥតមានញាប់ញ័រ រឹស្កន់ជាន់ដូចពីឆ្នាំ១៩៥៣នោះទេ។ ខ្ញុំធាក់កង់របៀបរើយសំដៅទៅផ្ទះ ខ្ញុំជួលនៅឯមេភ្លើង។ ទៅដល់ផ្ទះ ខ្ញុំហែកសំបុត្រមើល ខ្ញុំឃើញក្រដាសប្រាក់ប្រាំរយរៀលបីសន្លឹកយ៉ាងថ្មីស្រឡាង ភ្ជាប់និងកូនសំបុត្រតូចមួយ ដែលសរសេរមិនខុសគ្នាពីឆ្នាំ១៩៥៣នោះទេ : «សូមហ៊ាយកលុយនេះសម្រាប់ទិញសៀវភៅរៀន»។

យប់នោះ ភ្នែករបស់ខ្ញុំវាបើករហូតទាល់ភ្លឺ។ ខ្ញុំរវើរវាយទាល់តែថ្ងៃរះ ទើបដេកលក់...



# ផ្សែងម្តាយក្មេក

**ឃ្មុំហើរចោលសំបុក កើតទុក្ខព្រោះផ្សែង**
**អាឆៃចំបែង ព្រោះផ្សែងម្តាយក្មេក។**

**ទូច គិមសួគ៌**

ដោយសាររឿងស្នេហា អាឆៃប្រលងធ្លាក់ ហើយមិនបានចូលរៀនវិទ្យាល័យព្រះសីហនុនឹងគេទេ។ ក្រោយមក អាឆៃរកបានការធ្វើនៅចំការកៅស៊ូជប់ក្បែរស្រុកសួង។ ហេតុតែគូព្រេងពីអតីត អាឆៃបានរៀបការជាមួយនាងចាន់ធូទៅ។ ក្រោយពីការរួច ថៅកែតនអោយវាឈប់ធ្វើការ ទៅជួយរកស៊ីគាត់។ អាឆៃត្រូវតស៊ូ និងមានចិត្តធ្ងន់ណាស់ ព្រោះម្តាយក្មេកវាឆ្នាសពេកកន្លង កូនមានប្តីហើយនៅតែវាយប្រដៅដូចកូនក្មេង។ មិនត្រឹមតែវាយនាងចាន់ធូទេ ជួនកាលគាត់វាយផល់អាឆៃរត់ចេញពីផ្ទះ តែខោខ្លីមួយចង្កេះ។ មួយសន្ទុះធំក្រោយមក នៅពេលម្តាយបាត់ខឹង ទើបនាងចាន់ធូដើរទៅរកប្តីអោយមកផ្ទះវិញ។ គួរអោយអាណិតអាឆៃណាស់ តែមិនដឹងធ្វើដូចម្តេចទេ ព្រោះព្រហ្មលិខិតចារមកអ៊ីចឹងទៅហើយ។

២០ឆ្នាំក្រោយមក គឺនៅឆ្នាំ១៩៧៣ ក្រោយពេលដែលពួកបិសាចខ្មែរក្រហមវាយខេត្តកំពង់ចាម អាឆៃក៏នាំគ្រួសារ ព្រមទាំងឪពុកម្តាយក្មេកវាមកនៅភ្នំពេញ ក្បែរពេទ្យលោកសង្ឃមិនឆ្ងាយប៉ុន្មានពីផ្ទះខ្ញុំទេ។

វាមានកូន៤នាក់ ហើយរកស៊ីលក់សាំង។ ជីវភាពគ្រួសារអាឆៃធូរធារណាស់ តែម្ដាយក្មេករបស់វានៅតែកាចដដែល គឺកាចជាងកាលពីនៅកំពង់ចាមទៅទៀត។ អាឆៃខ្លាចម្ដាយក្មេក។ ប្រពន្ធវាអាណិតប្ដីស្ទើរខ្លោចចិត្ត តែមិនដឹងធ្វើដូចម្ដេច ព្រោះខ្លួនឯងក៏ខ្លាចម្ដាយដែរ។ នៅពេលខ្ញុំទៅលេងផ្ទះវាម្ដងៗ ម្ដាយក្មេកវាក្ដី ប្រពន្ធវាក្ដី សប្បាយចិត្តណាស់ ព្រោះខ្ញុំបានកំដរបរិយាកាសនិងរៀបរាប់អនុស្សាវរីយ៍ចាស់ៗកាលនៅវត្តបឹងកុក។ ប្រពន្ធវាតែងតែខ្សឹបដាក់ត្រចៀកខ្ញុំថា សុំអោយខ្ញុំមកលេងអោយបានញឹកញាប់បន្តិច ព្រោះបើមានវត្តមានខ្ញុំ មីងឈនគាត់ស្លូតណាស់ មិនរករឿងអាឆៃប្ដីនាងឡើយ។ មីងឈននេះពិតជាកប៉ាល់ភ្លើងមែន អោយតែមានរឿងមិនពេញចិត្ត គាត់រករឿងអាឆៃ រឺប្រពន្ធវាភ្លាម។





ថ្ងៃ១៧មេសា ១៩៧៥ ពួកទមិឡចូលដល់ក្រុងភ្នំពេញ។ វាដេញប្រជាជនចេញពីទីក្រុង។ អាឆៃព្រមទាំងគ្រួសារបើកឡានមករកខ្ញុំជាបន្ទាន់ យើងទាំងពីរគ្រួសារក៏នាំគ្នាធ្វើដំណើរចេញពីក្រុងទាំងអស់គ្នា។ យើងនាំគ្នាដើរតាមមាត់ទន្លេ សំដៅទៅទីក្រុងកំពង់ចាម។ អស់រយៈពេលពីរខែ ទើបយើងទៅដល់ស្រុកសួង។ មកដល់ស្រុកសួង ពួកទមិឡក៏ដឹកយើងទាំងពីរគ្រួសារអោយមកស្នាក់នៅភូមិថ្នល់ ស្រុកតំបែរគោកស្រុក ក្នុងខេត្តកំពង់ចាម។

មកដល់ភូមិថ្នល់ ពួកទមិឡឥតសាសនាអោយយើងសង់រោងពីររោងមួយនៅខាងកើតភូមិ រោងមួយទៀតនៅខាងលិចភូមិ។ អាឆៃនៅ«វាំង» (ជាពាក្យសើចលេងជាមួយអាឆៃ) ខាងលិច ខ្ញុំនៅ«វាំង» ខាងកើត។ រោងឫស្សីនីមួយៗមានប្រវែងប្រហែល៣០ម៉ែត្រ ប្រសិនណាបើ

អ្នកណាមួយហ៊ានប្រតិបត្តិការសិកនៅពេលយប់ គឺច្បាស់ជារង្គើគ្មាននរណាដេកបានឡើយ។ អាឆៃដោយសារធ្វើការហេវហត់ពេក វាមិនបានបំរើឪពុកម្តាយក្មេក ដូចកាលនៅសង្គមចាស់ទេ។ តែមកដល់រោងវាលូនចូលដេកតែម្តង។ ម្តាយក្មេកវាជាមនុស្សចិត្តអាក្រក់ណាស់ ជេរកូនប្រសាមិនស្វាង។ ណាមួយហេវហត់ ណាមួយឥតមានបាយស៊ី អាឆៃមួម៉ៅហ៊ានឆ្លើយតបនឹងម្តាយក្មេក។ ចាប់តាំងពីអាឆៃតមាត់គាត់ គាត់ប្រមូលមាសពេជ្រពីប្រពន្ធវាមកទុកខ្លួនឯង។ បែបខ្លាចអាឆៃយកមាសទៅជូវអង្គរពួកទមិឡក៏មិនដឹង។ ល្ងាចមួយនោះ អាឆៃមកដល់រោង យប់ងងឹតខ្លាំងណាស់ទៅហើយ វាក៏យកទឹកមួយថាំងដែលប្រពន្ធវារែកទុកអោយម៉ែមកងូត។ កំពុងលាបខ្លួន ម្តាយក្មេកវាជេរបញ្ជោរថា អាឆៃឥលូវផល់ថ្នាក់ងូតទឹកក្នុងផ្ទះហើយ។ ចាប់តាំងពីថ្ងៃនោះមក អាឆៃចូលរាំងខាងលិចលែងបាន ព្រោះម្តាយក្មេកវាជេរមិនស្វាង ហើយថែមទាំងបង្គាប់អោយកូនគាត់លែងប្តីថែមទៀត។ វាក៏រត់ទៅនៅរាំងឯកើតជាមួយនឹងខ្ញុំ។

ថ្ងៃមួយ អង្គការចាត់អាឆៃអោយទៅលើកទំនប់ ស្រាប់តែឃើញឡានកាមីញ៉ុងពីរបើកចូលមកក្នុងភូមិ។ ពួកទមិឡពីរបីនាក់ កាំភ្លើងនៅដៃដើរទៅប្រមូលពួករោងខាងលិចអោយឡើងឡាន ព្រោះអង្គការត្រូវលើកទិសថ្មី។ ប្រពន្ធអាឆៃទឹកភ្នែករលីងរលោង ស្រែកអង្វរពួកបិសាចសុំនៅភូមិថ្មលល់តទៅទៀត ព្រោះប្តីគាត់ទៅលើកទំនប់មិនទាន់មកផង។

- តែអង្គការលើកទិសហើយ(ទមិឡម្នាក់និយាយ) គ្មាននរណាអាចជំទាស់បានទេ។ ភ្លាមឡើង១។

ប្រពន្ធអាឆៃ កូនរបស់វា ព្រមទាំងឪពុកម្តាយក្មេក នាំគ្នាឡើងលើឡានទាំងទឹកភ្នែក។ គ្មាននរណាម្នាក់ដឹងថា តើអង្គការដឹកពួកថ្មីទៅឯណាឡើយ។



ចុងឆ្នាំ១៩៧៨... កងទ័ពរណសិរ្សនិងកងទ័ពវៀតណាមវាយលុកចូលស្រុកខ្មែរ។ ខ្មែរក្រហមព្យួតែយូន នាំគ្នារត់ប្រាសអាយូស។ ពួកអាស្អីគេនេះ បានតែជាមួយខ្មែរគ្នាឯងទេ។ គ្រួសារខ្ញុំព្រមទាំងអាឆៃនាំគ្នារត់ចេញពីភូមិសំដៅទៅក្រុងកំពង់ចាម។ ខ្ញុំនាំកូនប្រពន្ធទៅនៅភ្នំពេញ រីឯអាឆៃត្រលប់ទៅផ្ទះប្រពន្ធវានៅបឹងកុក រង់ចាំមើលប្រពន្ធកូនវា។

៦ខែក្រោយមក ខ្ញុំទៅផល់ជំរំខៅអ៊ីដាង ឯស្រុកសៀម។ ជនភៀសខ្លួនខ្មែរជាច្រើនម៉ឺននាក់ នាំគ្នារស់នៅយ៉ាងណែនណាន់តាន់តាប់ក្នុងជំរំដែលសង់នៅលើផ្ទៃដីដ៏ធំធេង។ នៅក្នុងជំរំ គេឃើញមានវិហារកាតូលិកមួយយ៉ាងធំ។ ជនភៀសខ្លួនជាច្រើនរយនាក់ នាំគ្នាចូលសាសនា



កាតូលិក ដោយសង្ឃឹមយ៉ាងមាំថា ព្រះយេស៊ូគ្រិស្តមុខជានឹងជួយគេអោយឆាប់បានចេញពីជំរំទៅកាន់ប្រទេសទី៣ មានអាមេរិច បារាំងជាដើម។ ព្រឹកថ្ងៃមួយនោះ នៅពេលខ្ញុំដើរលេងក្នុងជំរំ ស្រាប់តែវូមវាក់នឹងអាឆៃ។ វាកាន់គម្ពីរ«ប៊ីប» មួយយ៉ាងធំនៅដៃស្តាំ។ អាឆៃស្ទុះមកអោបខ្ញុំទាំងទឹកភ្នែក។

- អាសំលាញ់អើយ(អាឆៃនិយាយ) ប្រពន្ធកូនអញស្លាប់អស់ហើយមើលទៅ ព្រោះអញខំដើររកតាំងពីនៅកំពង់ចាមរហូតដល់ភ្នំពេញមិនឃើញសោះ។

ខ្ញុំអាណិតអាឆៃស្ទើរខ្លោចចិត្ត។

- ឯងឥលូវចូលយេស៊ូហើយរឺ អាឆៃ? (ខ្ញុំសួរទៅវា)។

- អញដាច់ចិត្តចូលកាតូលិកហើយ ព្រោះព្រះ(ពុទ្ធ) ឥតជួយអញទេ។ អញនៅវត្តប្រឹងបំរើព្រះសឹងស្លាប់ ព្រះឥតជួយអញសោះ។ អញតូចចិត្តនឹងព្រះខ្លាំងណាស់។

មួយអាទិត្យក្រោយមក អាឆៃរត់មករកខ្ញុំទាំងព្រឹកព្រហាម :

- អាសំលាញ់អើយ អញរកឃើញប្រពន្ធកូនអញហើយ។ ឥលូវនេះគ្រួសារអញនៅសង្កាត់លេខ២។ តែសំណាងអាក្រក់ណាស់ម្តាយក្មេកអញនៅរស់ ហើយគាត់មិនព្រមអោយអញរួមរស់ជាមួយប្រពន្ធអញទេ ព្រោះគាត់ថា អញជាកូនអកតញ្ញូកាលនៅជំនាន់អាពត។

នៅពេលខ្ញុំជួបប្រពន្ធអាឆៃ គាត់រលឹងរលោងទឹកភ្នែក និយាយមកកាន់ខ្ញុំ :

- ពូវាអើយ ម៉ែគាត់ប្រកាន់ខឹងនឹងឪវា អោយខ្ញុំលែងគាត់។ ខ្ញុំលែងប្តីមិនកើតទេ តែម្តាយខ្ញុំចាស់ ហើយឈឺទៀតផង។ ដូចនេះ ខ្ញុំសុខចិត្តធ្វើតាមគាត់មួយគ្រាសិន ដល់គាត់អស់ជីវិត ខ្ញុំមុខជាទៅរកឪវាវិញហើយ។ ពូវាអើយជួយទៅពន្យល់ប្តីខ្ញុំផង។



ខ្ញុំយករឿងនេះមកប្រាប់អាឆៃ។

- តើថ្ងៃណាទៅអាំ បានគាត់ងាប់? (អាឆៃនិយាយមកកាន់ខ្ញុំ)។

រឿងម្តាយក្មេកអាឆៃធ្វើបាបកូនប្រសា អ្នកនៅក្នុងជំរំគេដឹងឮសឹងគ្រប់គ្នា។

កន្លះឆ្នាំក្រោយមក ម្តាយក្មេកអាឆៃក៏បានចែកឋានទៅមែន។ អាឆៃក៏បានទៅជួបជុំគ្រួសារវាជាថ្មីម្តងទៀត។ ជួបគ្នាម្តងនេះ ពិតជាជួបរហូតជួបដល់ខាំចេករបូត ខាំពោតរបេះ។

ថ្ងៃមួយ នៅពេលដែលគ្រួសារយើងទាំងពីរជួបជុំគ្នានៅឯស្រុកស្វីស (Suisse) ខ្ញុំនិយាយទៅកាន់ប្រពន្ធអាឆៃថា :

- មឹងវាដឹងទេ អាឆៃវាមានបាប ព្រោះកាលនៅវត្តថ្មគោល និងបឹងកុក វាបាននាំខ្ញុំលួចស៊ីបាយមុនលោក។ ព្រះលោកខ្វាល់ទើបដាក់ទណ្ឌកម្មវា។

## *កំណត់សំគាល់*

*ទំព័រ៩*

[១] *សង្ឃរាជ អ្នកគ្រប់គ្រងបណ្ដាសង្ឃ ហើយមានឋានៈធំជាងគេក្នុងវត្ត អាចហៅម្យ៉ាងទៀតថា លោកចៅអធិការវត្ត។*

*ទំព័រ១៥*

[២] *«ខ្ញុំកាណា» ជាភាសានិយាយ ឯភាសាសរសេរគឺ«ខ្ញុំករុណា» ដែលមានន័យថា«ខ្ញុំ»។ រីឯពាក្យ«កាណា» ដែលចេញមកពីភាសាសរសេរ«ករុណា» គេប្រើវាសំរាប់ឆ្លើយជំនួសពាក្យ«ខ្ញុំ» «បាទ» រឺ «ចាស»។ គ្រហស្ថ(មនុស្សសាមញ្ញមិនមែនអ្នកបួស) ត្រូវប្រើពាក្យ«ខ្ញុំករុណា» និង«ករុណា» នៅពេលនិយាយទៅកាន់សង្ឃ(អ្នកបួស) រីឯសង្ឃក៏ត្រូវប្រើពាក្យនេះជំនួសពាក្យ«ខ្ញុំ» និង«បាទ»ធម្មតាដែរ នៅពេលដែលលោកនិយាយទៅកាន់សង្ឃដូចគ្នា។*

[៣] *ល្បល់យក៏ ជាភាសានិយាយ សំដៅទៅលើពាក្យជេរដោយទ្រគោះ។ ភាសាសរសេរគឺ រំបល់យក៏!*

*ទំព័រ១៧*

[៤] *វិធីលូកសំណនេះជាក្បួនចិត្តសាស្ត្រមួយដែលព្រះសង្ឃតែងតែយកមកប្រើបន្ទាចក្មេងណាដែលមានដៃមានជើង ដើម្បីអោយវាសារភាពកំហុស។ គេដាំសំណអោយរលាយនៅក្នុងកូនឆ្នាំង រួចបន្ទាចក្មេងថា អាណាលួចគេពេលលូកទៅនោះ សំណជាប់ដៃរហូត។ ក្មេងមានខ្លួនភ័យខ្លាចសំណជាប់ដៃ វាពិតជាសារភាពកំហុស។ នេះគឺជាវិធីរកចោរអំបុកចោរអំបែង។*

*ទំព័រ៣៦*

[៥] *វេរភត្ត គឺប្រគេនចង្ហាន់សង្ឃ។ នៅទីនេះមានន័យថា អោយចំណីឆ្កែ។*

[៦] *«canard osé pied rouge» ជាភាសាបោយ គឺភាសាអ្នកបំរើដែលចេះភាសាបារាំងតិចតួច។ នៅទីនេះ គេបកពាក្យទាហានជើងក្រហមដោយ«canard» ដែលមានន័យថា«ទា» «osé» ដែលមានន័យថាហ៊ាន «pied» ដែលមានន័យថា«ជើង» និង«rouge» ដែលមានន័យថា«ក្រហម»។*

[៧] *«canard osé pied noir» ជាភាសាបោយ ដូចគ្នានឹង«canard osé pied rouge» ដែរ គ្រាន់តែជំនួសពាក្យ«rouge» ដោយពាក្យ«noir» ដែលមានន័យថា«ខ្មៅ» តែប៉ុណ្ណោះ។*

*ទំព័រ៤១*

[៨] *ជំនាន់នោះ ខ្មែរយើងនាំគ្នានិយាយថា«លោតម៉ាដាំ» តែបើនិយាយថា«ម៉ាដាំលោត»វិញ ប្រហែលជាត្រូវជាង។ ពាក្យថាម៉ាដាំ បើតាមខ្ញុំយល់គឺមកពីពាក្យបារាំង«Madame»។ ខ្មែរយើងជំនាន់អាណានិគមតែងតែហៅស្រីបារាំងស្លៀករ៉ូបថាម៉ាដាម១។ អ្នករាំបើកឆាកល្ខោនជាស្ត្រីភេទ ហើយស្លៀករ៉ូបរបៀបស្ត្រីបារាំង។ ហេតុដូចនេះហើយបានជាយើងទំលាប់ហៅ«លោត ម៉ាដាំ» ព្រោះវាពីរោះស្តាប់ជាង«ម៉ាដាំលោត»។*

*ទំព័រ៦១*

[៩] *អ្នកនិពន្ធបារាំងនៅសតវត្សរ៍ទី១៨ ដែលស្រលាញ់ធម្មជាតិ និងចូលចិត្តធ្វើដំណើរដោយជើង(voyage à pied)។ «On part à son moment, on s'arrête à sa volonté. Aperçois-je une rivière, je la côtoie...» ចេញដំណើរថ្មើរម៉ានក៏បាន យើងឈប់កន្លែងណាស្រេចតែនឹងចិត្តយើង។ បើប្រទះនឹងស្ទឹង ខ្ញុំដើរសសៀរតាមមាត់ច្រាំង...*